00285105

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C22/5/24

**អង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ:** ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៧)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ២៧ កុម្ភៈ ២០០៩

---

**សាធារណៈ**

## សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចដោយផ្ទាល់មាត់ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ លើសំណើដែលបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងពេលសវនាការ

---

**<u>ការិយាល័យសហព្រះរាជអាជ្ញា</u>**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**<u>ជនត្រូវចោទ</u>**

អៀង សារី

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

ហុង គឹមសួន
ឡេ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE
David BLACKMAN

**<u>សហមេធាវីការពារក្តី</u>**

អាង ឧត្តម
MichaelG. ARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 02 / MAR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 02 / 2009
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

00285106



១. អង្គបុរេជំនុំជម្រះ កត់សម្គាល់ឃើញមានសំណើចំនួនបី ដែលបានដាក់ជូននៅចំពោះមុខខ្លួន មុនពេលសវនាការ និងក្នុងអំឡុងពេលសវនាការ៖

១-ស្ដាប់សក្ខីកម្មរបស់វេជ្ជបណ្ឌិត Falke នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

២-ពន្យារពេលសវនាការ ដោយសារស្ថានភាពសុខភាពរបស់ជនត្រូវចោទ

៣-បន្តសវនាការដើម្បីឲ្យសហមេធាវីការពារក្ដីរបស់ជនត្រូវចោទ ធ្វើសេចក្ដីសន្និដ្ឋានថា ហេតុអ្វីបញ្ហាសុខភាព មានភាពចាំបាច់សម្រាប់អង្គបុរេជំនុំជម្រះពិចារណា។

២. នៅក្នុងសំណើទី១៖

អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើនេះគឺសុំឲ្យស្ដាប់សក្ខីកម្មរបស់វេជ្ជបណ្ឌិត Falke ក្នុងឋានៈជាសាក្សី ដោយមិនតែងតាំងគាត់ជាអ្នកជំនាញ។ ភស្ដុតាងដែលគាត់អាចផ្ដល់ជូន គឺជាភស្ដុតាងដោយប្រយោល។ ដូច្នេះ សំណើនេះត្រូវបានបដិសេធចោល។

៣. នៅក្នុងសំណើទី២៖

អង្គបុរេជំនុំជម្រះ ទទួលយកសំណើសុំពន្យារពេលសវនាការលើបណ្ដឹងឧទ្ធរណ៍ ដោយសារស្ថានភាពសុខភាពរបស់ជនត្រូវចោទ។ អង្គបុរេជំនុំជម្រះ យល់ឃើញថា របាយការណ៍របស់វេជ្ជបណ្ឌិតនៃមន្ទីឃុំឃាំង ដែលទើបតែបានផ្ដល់ជូនអង្គបុរេជំនុំជម្រះមុនពេលសវនាការ គ្រប់គ្រាន់ចំពោះការសន្និដ្ឋាន នេះ។

៤. នៅក្នុងសំណើទី៣៖

អង្គបុរេជំនុំជម្រះ កត់សម្គាល់ឃើញថា សហមេធាវីការពារក្ដីបានសន្និដ្ឋានថា បញ្ហាសុខភាពរបស់ជនត្រូវចោទដែលខ្លួនចង់លើកឡើង គឺជាផ្នែកមួយនៃបណ្ដឹងឧទ្ធរណ៍។

ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បញ្ហានេះគួរលើកឡើងក្នុងពេលសវនាការលើបណ្ដឹងឧទ្ធរណ៍ទាំងមូល។

C22/5/24

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៧)

អង្គបុរេជំនុំជម្រះ កត់សម្គាល់ឃើញទៀតថា នាពេលនេះ អង្គបុរេជំនុំជម្រះ មិនទទួលបាន សំណើបន្ថែម ដែលមានលក្ខណៈជាក់លាក់ ដូចដែលអង្គបុរេជំនុំជម្រះបានលើកឡើងនៅក្នុង សេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៨។

**ដូច្នេះ អង្គបុរេជំនុំជម្រះ÷**

សម្រេចពន្យារពេលសវនាការរហូតដល់ ថ្ងៃទី**២ ខែមេសា ឆ្នាំ២០០៨** វេលា ម៉ោង **៩ព្រឹក**។

សេចក្តីសម្រេចនេះ បានប្រកាសដោយផ្ទាល់មាត់ក្នុងពេលសវនាការ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨។

ភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**